# អាស៊ានក្នុងសង់ស៊ុស និងឥទ្ធិពលមហាអំណាចក្នុងតំបន់

ដោយ៖ លោក អ៊ុច លាង អ្នកសិក្សាស្រាវជ្រាវនៃនាយកដ្ឋានសិក្សាអាស៊ី អាហ្វ្រិក និងមជ្ឈិមបូព៌ា
នៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃកម្ពុជា នៃរាជបណ្ឌិត្យសភាកម្ពុជា

កម្ពុជាបានដើរតួនាទីជាផ្លូវការក្នុងការដឹកនាំអាស៊ានសម្រាប់ឆ្នាំ២០២២នេះ និងជាលើកទីបីផងដែរ សម្រាប់ប្រធានប្តូរវេនរបស់កម្ពុជា ចាប់តាំងពីបានចូលជាសមាជិកអាស៊ាននាឆ្នាំ១៩៩៩។ ឆ្នាំ២០២២នៃប្រធានអាស៊ានរបស់កម្ពុជានាពេលនេះ គឺផ្តោតលើមូលបទសំខាន់ «អាស៊ានរួមគ្នាធ្វើះដោះស្រាយបញ្ហាប្រឈមទាំងអស់គ្នា ហើយនិមិត្តសញ្ញាគឺ ត្របកឈូកគឺជាទម្រង់ក្បាច់ខ្មែរ តំណាងឱ្យភាពរុងរឿង និងភាពសុខដុមរមនានៃសន្តិភាពដែល ប្រទេសសមាជិកអាស៊ានទាំង១០ បានខិតខំបង្កើតឡើង។ ពណ៌ទាំងបីនៅលើស្រទាប់របស់វា គឺបានមកពីពណ៌នៃទង់ជាតិកម្ពុជា ចំណែកពណ៌មាសតំណាងឱ្យពណ៌ និង ភាពចម្រុះនៃអាស៊ាន។ «ស្មារតីស្នូលរបស់អាស៊ានគឺ ភាពរួបរួមគ្នា សាមគ្គីភាព និងភាពសុខដុមរមនា! ចំណែក គោលបំណងសំខាន់គឺ រក្សាឱ្យបាននូវមជ្ឈភាព និងសាមគ្គីភាពរបស់អាស៊ាន រួមគ្នាដោះស្រាយបញ្ហាប្រឈម ធានាឱ្យបាននូវវឌ្ឍនភាពការងាររួមដែលមានស្រាប់ និងលើកកម្ពស់ការផ្តោតសំខាន់ទៅលើមនុស្សជាតិ»។ លទ្ធផលរំពឹងទុករួមមាន «សេចក្តីថ្លែងការណ៍រួម និងសេចក្តីថ្លែងការណ៍របស់ប្រមុខដឹកនាំអាស៊ាន ការបន្តផែនការការងារ និងផែនការសកម្មភាព ព្រមទាំងការរៀបចំព្រឹត្តិការណ៍ និងសកម្មភាពសំខាន់ៗទាំងអស់។ កម្ពុជាបានត្រៀមខ្លួនរួចជាស្រេច ពោរពេញទៅដោយទំនួលខុសត្រូវ ហើយកម្ពុជានឹងបំពេញតួនាទីនេះដោយមោទនភាពបំផុត» នេះយោងតាមសេចក្តីប្រកាសរបស់ ឯកឧត្តម ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា។

ចាប់តាំងពីកម្ពុជាចូលកាន់តំណែងជាប្រធានអាស៊ាននាឆ្នាំ២០២២ បន្តវេនពីប្រទេសប្រ៊ុយណេមក បញ្ហាកុងសង់ស៊ុសរបស់សមាជិកអាស៊ាន ចេះតែកើតមានជាបន្តបន្ទាប់ ដូចជា៖ កិច្ចប្រជុំចង្អៀតរដ្ឋមន្ត្រីការបរទេសអាស៊ាន (AMM Retreat) ដែលគ្រោងរៀបចំធ្វើនៅថ្ងៃទី ១៨-១៩ ខែមករា ឆ្នាំ២០២២ នៅខេត្តសៀមរាប ត្រូវបានលើកទៅ ថ្ងៃទី១៦-១៧ ខែកុម្ភៈ ឆ្នាំ២០២២វិញ ដោយកង្វះកុងសង់ស៊ុស។ កិច្ចប្រជុំកំពូលពិសេសអាស៊ាន-អាម៉េរិក ដែលគ្រោងនឹងធ្វើឡើងនៅថ្ងៃទី២៨-២៩ ខែមីនា ឆ្នាំ២០២២ នេះក៏ត្រូវបានលើកពេលផងដែរ ដោយហេតុផលថា «សហរដ្ឋអាម៉េរិក ធ្លាប់បានប្រកាសកំណត់យកថ្ងៃទី ២៨-២៩ មីនា ដើម្បីរៀបចំកិច្ចប្រជុំនេះ ដែលបច្ចុប្បន្នមានប្រទេសឥណ្ឌូនេស៊ីគឺជាប្រទេសសម្របសម្រួលទំនាក់ទំនងដៃគូសន្ទនារវាងអាស៊ាន និងសហរដ្ឋអាម៉េរិក។ បន្ទាប់ពីកាលបរិច្ឆេទត្រូវបានស្នើឡើង សម្រាប់កិច្ចប្រជុំកំពូលនេះ ឥណ្ឌូនេស៊ីបានខិតខំអស់ពីសមត្ថភាពក្នុងការសម្របសម្រួល ដើម្បីស្វែងរក កាល បរិច្ឆេទ

មួយដែលអាចទទួលយកបានដោយថ្នាក់ដឹកនាំទាំងអស់ ប៉ុន្តែគួរឱ្យសោកស្តាយ កាលបរិច្ឆេទ ដែលបានស្នើឡើង គឺមិនសមស្របសម្រាប់ថ្នាក់ដឹកនាំអាស៊ានដោយសារភាពជាប់រវល់ច្រើនរបស់ថ្នាក់ដឹកនាំ។ ហេតុនេះហើយ ភាគីទាំងសងខាង អាស៊ាននិងសហរដ្ឋអាម៉េរិក បានសម្រេចលើកពេលកិច្ចប្រជុំកំពូលនេះ ហើយនិងបន្តធ្វើការដើម្បីស្វែងរកកាលបរិច្ឆេទ ដែលសមស្របសម្រាប់ភាគីទាំងសងខាង» នេះបើយោងតាម អ្នកនាំពាក្យរបស់ក្រសួងការបរទេសកម្ពុជា។

នេះជាភាពអាក់អួលមួយនៃដំណើរការជាប្រធានប្តូរវេនរបស់កម្ពុជា។ តើនេះជាចេតនារបស់រដ្ឋជាសមាជិករបស់អាស៊ានមួយចំនួនឬក្រោមឥទ្ធិពលរបស់មហាអំណាច?

សូមរំលឹកថា កាលពីអតីតកាល ជាពិសេសនៅចន្លោះទសវត្សរ៍ទី៦០និងទសវត្សរ៍ទី៧០ បណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ តែងតែចាត់ទុកចិនកុម្មុយនិស្ត ជាប្រទេសដែលគ្រោះថ្នាក់ធំបំផុត។ ជាពិសេសនៅឆ្នាំ១៩៧៩ បណ្តាប្រទេសនៅ អាស៊ីអាគ្នេយ៍ ភាគច្រើន នាំគ្នាចាត់ទុកប្រទេសចិនថា ជាប្រទេសដែលមានភាពគ្រោះថ្នាក់បំផុត ផ្អែកយោជា គឺនៅពេលដែល កងទ័ពចិនបានវាយប្រហារទៅលើប្រទេសវៀតណាម (វៀតណាមខាងជើង) ដោយហេតុថា វៀតណាម បានវាយចូលមកផ្តួលរំលំរបបខ្មែរក្រហម ដែលកំពុងគ្រប់គ្រងប្រទេសកម្ពុជា និងបានបន្តគ្រប់គ្រងប្រទេសកម្ពុជា។

រហូតមកទល់សព្វថ្ងៃនេះ បណ្តាប្រទេសសមាជិកទាំង១០របស់អាស៊ាន មានទំនាក់ទំនងល្អជាមួយចិន។ មិនតែប៉ុណ្ណោះ អាស៊ានថែមទាំងគាំទ្រចិន និងទទួលស្គាល់គោលការណ៍ប្រទេសចិនតែមួយនៅលើឆាកអន្តរជាតិទៀតផង។ នេះគឺដោយសារ តាំងពីដើមទសវត្សរ៍ទី៩០មក ចិនបាននឹងកំពុងបន្តជំរុញនយោបាយការទូតសេដ្ឋកិច្ច វប្បធម៌ និងនយោបាយដ៏ប៉ិនប្រសប់របស់ខ្លួន ចូលមកតំបន់អាស៊ីអាគ្នេយ៍។ ចិនប្រើអំណាចទន់ (The soft power) និងអនុវត្តនយោបាយ«ឈ្នះឈ្នះ» ក្នុងគោលដៅពង្រីកឥទ្ធិពលរបស់ខ្លួននៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ តាមរយៈនយោបាយអំណាចទន់នេះ ចិនក៏បានពង្រីកឥទ្ធិពលវប្បធម៌របស់ខ្លួនទៅលើភូមិភាគអាស៊ីអាគ្នេយ៍ផងដែរ។ ខ្សែភាពយន្តចិន សិល្បៈធ្វើម្ហូបអាហារចិន និងផលិតផលឧបភោគបរិភោគ ដែលផលិតនៅប្រទេសចិន (made in China) កំពុងជួយធ្វើឱ្យកេរ្តិ៍ឈ្មោះរបស់ចិន ល្បីសុះសាយពេញទូទាំងតំបន់អាស៊ីអាគ្នេយ៍។

សូមរំលឹកថា ចាប់តាំងពីឆ្នាំ១៩៩១ ថ្នាក់ដឹកនាំនៃបណ្តាប្រទេសក្នុងតំបន់ អាស៊ាន និងចិន បានបង្កើតទំនាក់ទំនង សន្ទនាជាផ្លូវការ ហើយរហូតមកទល់ពេលនេះ ភាគីទាំងពីរ បានឯកភាពគ្នាបង្កើតទៅជា «ភាពជាដៃគូយុទ្ធសាស្ត្រ គ្រប់ជ្រុងជ្រោយ» ដោយការទទួលស្គាល់ថា ទំនាក់ទំនងអាស៊ាន-ចិន គឺស្ថិតក្នុង ចំណោមទំនាក់ទំនងដែលប្រកបដោយថាមវន្តបំផុត មានសារៈសំខាន់ និងផ្តល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក និងបានរួមចំណែកដល់ការថែរក្សាសន្តិភាព ស្ថិរភាព អភិវឌ្ឍន៍ និង

វិបុលភាព នៅក្នុងតំបន់ ដោយខិតខំរក្សាស្ថិរភាពក្នុងតំបន់ ជំរុញការតភ្ជាប់គ្នា ពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ចនិងពាណិជ្ជកម្ម និងបង្កើនទំនាក់ទំនងលើវិស័យវប្បធម៌។ ទំនាក់ទំនង អាស៊ាន-ចិន ប្រកបដោយភាពរស់រវើក និងធំបំផុតក្នុងកិច្ចសហប្រតិបត្តិការក្នុងតំបន់អាស៊ី-បាស៊ីហ្វិក ហើយបាននាំមកនូវផលប្រយោជន៍ ដ៏ធំធេង ជូនដល់ប្រជាជនជាង ២០០០ លាននាក់ នៃប្រទេសចំនួន១១ ក្នុងតំបន់។

ក៏ប៉ុន្តែ ទោះបីជាទំនាក់ទំនងរវាងចិន និងអាស៊ានមានលក្ខណៈកាន់តែប្រសើរពីមួយឆ្នាំទៅមួយឆ្នាំក៏ដោយ ក៏តាំងពីដើមដំបូងមក ថ្នាក់ដឹកអាស៊ានតែងតែប្រកាន់យ៉ាងខ្ជាប់ខ្ជួន នូវគោលការណ៍មួយច្បាស់ នោះគឺ ធ្វើយ៉ាងណាកុំឱ្យអាស៊ីអាគ្នេយ៍ស្ថិតនៅក្រោមឥទ្ធិពលផ្តាច់មុខរបស់ចិនបាន (ពេលនេះគឺ ផ្តាច់មុខរបស់មហាអំណាចណាមួយ ក្នុងចំណោមចិន និងអាម៉េរិក)។ ការណ៍នេះគឺមិនមែនថៃជន្យឡើយ។ ចូរកុំភ្លេចថា គោលដៅសំខាន់ជាងគេមួយនៃការបង្កើតសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ឡើងនៅឆ្នាំ១៩៦៧ គឺដើម្បីបង្រួបបង្រួមគ្នា ដើម្បីទប់ទល់នឹងគ្រោះថ្នាក់ពីសំណាក់របបកុម្មុយនិស្ត។

នាពេលបច្ចុប្បន្ននេះ ថ្នាក់ដឹកនាំចិនតែងតែលើកឡើងថា ចិនចង់បានតែសន្តិភាពនិងស្ថិរភាពនៅក្នុងតំបន់។ ក៏ប៉ុន្តែ កាយវិការរបស់ទីក្រុងប៉េកាំង មិនទាន់ស្តែងឱ្យឃើញច្បាស់នៅឡើយទេថា ចិនជាប្រទេសមហាអំណាច ដែលនិយមអំណាចទន់ (The soft power)។ ជាក់ស្តែង មហិច្ឆតារបស់ទីក្រុងប៉េកាំង នៅក្នុងតំបន់សមុទ្រចិនខាងត្បូង នៅតែបន្តបង្កឱ្យមានភាពតានតឹងកើតឡើងជារឿយៗ។ ភាពតានតឹងចេះតែបន្តកើតឡើងរវាងចិន និងបណ្តាប្រទេសអាស៊ានមួយចំនួន ជាអាទិ៍ជាមួយ វៀតណាម ហ្វីលីពីន ម៉ាឡេស៊ី និងព្រុយណេ។

នៅក្នុងបរិបទនៃភាពតានតឹងបែបនេះហើយ ដែលអាស៊ានបានបើកទទួលសហរដ្ឋអាម៉េរិកតាមរយៈ ជំនួបកំពូលអាស៊ាន-អាម៉េរិក ដែលបានកើតឡើងតាំងពីឆ្នាំ២០០៩រៀងមក។ ការខិតចូលជិតគ្នារវាងសហរដ្ឋអាម៉េរិកនិងអាស៊ាន បានធ្វើឱ្យកើតមានភាពល្អក់កករ ដល់ទំនាក់ទំនងរវាង ចិននិងអាស៊ាន ពីព្រោះថា វាបើកលទ្ធភាពឱ្យអាម៉េរិកបង្កើនវត្តមាន និងអំណាចរបស់ខ្លួន នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ គឺដើម្បីកាត់បន្ថយឥទ្ធិល និងអំណាចរបស់ចិននៅក្នុងតំបន់ ពិសេសគឺមិនចង់ឱ្យអាស៊ាន ស្ថិតនៅក្រោមមហាអំណាចផ្តាច់មុខណាមួយ។

ជាក់ស្តែង សហរដ្ឋអាម៉េរិក បានបង្ហាញពីតួនាទីដ៏ចាំបាច់របស់ខ្លួន ក្នុងតំបន់អាស៊ីអាគ្នេយ៍ នៅក្នុងដំណោះស្រាយនៃជម្លោះ នៅទីប្រជុំកោះ ParacelនិងSprately នៅសមុទ្រចិនខាងត្បូងជាដើម ហើយហូតមកទល់ពេលនេះ វត្តមានរបស់អាម៉េរិកនៅក្នុងវេទិកាអាស៊ាន បានបណ្តាលឱ្យមានការបាក់បែកគ្នារវាងរដ្ឋជាសមាជិកអាស៊ាន ដែលមានទំនោរទៅរកអាម៉េរិក និងរដ្ឋសមាជិកអាស៊ានដែលមានទំនោរទៅរកប្រទេសចិន បើទោះបីប្រទេសទាំងនោះបាន និយាយថាមិនជ្រើសយកខាងណាក៏ដោយ។

សម្រាប់កម្ពុជាដែលជាប្រទេសកូនពៅរបស់អាស៊ាន និងជាមិត្តលើសពីដែកថែបរបស់ចិន ផងទៀតនោះ ទោះបីចង់ឬមិនចង់ នៅក្នុងក្រសែភ្នែករបស់រដ្ឋជាសមាជិកអាស៊ានផ្សេងទៀត ដែលមាន ទំនោរទៅរកសហរដ្ឋអាម៉េរិក ពិតជាមានភាពលំបាកណាស់ ក្នុងការសម្រេចចិត្តជាមួយកម្ពុជា។ ការស្វែងរកកុងសង់ស៊ុសសម្រាប់កម្ពុជា ក្នុងឆ្នាំប្រធានអាស៊ានប្តូរវេន២០២២នេះ ដែលកំពុងតែប្រឈម ដោយការប្រកួតប្រជែងផ្នែកភូមិសាស្ត្រនយោបាយរបស់មហាអំណាច និងបញ្ហាសន្តិសុខមិនមែនប្រពៃណី (ការរីករាលដាលនៃវីរុសកូវីដ-១៩) នាពេលនេះ គឺពិតជានឹងពិបាកឈានទៅទទួលបានលទ្ធផលតាមការគ្រោងទុក៕